# សហគមន៍ខ្មែរកម្ពុជាក្រោម
## KHMER KAMPUCHEA KROM COMMUNITY
## LA COMMUNAUTÉ DU KHMER KAMPUCHEA KROM


លេខ..............................ស.ខ.ក.ក.

### សុន្ទរកថា

### ឯកឧត្តម ថាច់ សេដ្ឋា នាយកប្រតិបត្តិសហគមន៍ខ្មែរកម្ពុជាក្រោម
### សមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ និងជាអតីតសមាជិកព្រឹទ្ធសភា
### ក្នុងឱកាសខួបគំរប់៣៣ឆ្នាំ នៃថ្ងៃប្រជារាស្ត្រខ្មែរកម្ពុជាក្រោមក្រោកឡើង
### ទាមទារសិទ្ធិសេរីភាព នៅកម្ពុជាក្រោម នៅវត្តសាមគ្គីរង្សី
### រាជធានីភ្នំពេញ ១៦-១១-១៩៧៦ - ១៦-១១-២០០៩

សូមក្រាបថ្វាយបង្គំព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ

សូមគោរពវិញ្ញាណក្ខន្ធយុទ្ធជន យុទ្ធនារីខ្មែរស្នេហាជាតិដែលបានពលីជីវិតក្នុងព្រឹត្តិការណ៍ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៧៦ ជាទីគោរព

សូមគោរពជនរួមឈាមជាទីស្រឡាញ់ដ៏ជ្រាលជ្រៅ

ថ្ងៃនេះជាខួបគំរប់៣៣ឆ្នាំ នៃថ្ងៃប្រជារាស្ត្រខ្មែរកម្ពុជាក្រោមបានក្រោកឡើងតស៊ូទាមទារសិទ្ធិសេរីភាពរបស់ខ្លួនយ៉ាងអង់អាចក្លាហានជាទីបំផុត នៅលើទឹកដីកម្ពុជាក្រោម ។ ព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រដ៏អស្ចារ្យនេះ បានផ្តើមចេញពីការឈឺចាប់របស់ប្រជារាស្ត្រខ្មែរកម្ពុជាក្រោម ដែលទ្រាំលែងបានចំពោះទង្វើដ៏ឃោរឃៅអមនុស្សធម៌របស់អាណានិគមវៀតណាមដែលបានជិះជាន់ធ្វើបាបប្រជារាស្ត្រខ្មែរកម្ពុជាក្រោមគ្មានត្រាប្រណី ក្នុងគោលបំណងរំលាយពូជសាសន៍ខ្មែរ ឲ្យអស់ពីទឹកដីកម្ពុជាក្រោម (បច្ចុប្បន្នសាធារណរដ្ឋសង្គមនិយមវៀតណាមប៉ែកខាងត្បូង) ។

អង្គការ-សមាគមខ្មែរកម្ពុជាក្រោមដែលបានឯកភាពគ្នារៀបចំពិធីនេះឡើង គឺដើម្បី ៖

១-សម្តែងនូវការគោរព និងដឹងគុណយ៉ាងជ្រាលជ្រៅចំពោះវីរយុទ្ធជន យុទ្ធនារីខ្មែរស្នេហាជាតិទាំងអស់ដែលបានពលីជីវិត និងចូលរួមក្នុងព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៧៦ ក្នុងបុព្វហេតុសិទ្ធិសេរីភាព នៃប្រជារាស្ត្រខ្មែរកម្ពុជាក្រោម ។

ក្នុងព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រនេះ អាជ្ញាធរអាណានិគមវៀតណាមបច្ចុប្បន្ន (សាធារណរដ្ឋសង្គមនិយមវៀតណាម) បានប្រើប្រាស់កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ អមដោយរថក្រោះ រថពាសដែក បានធ្វើការបាញ់ប្រហារមកលើប្រជារាស្ត្រខ្មែរដែលគ្មានអាវុធយ៉ាងឃោរឃៅ បណ្តាលឲ្យស្លាប់ចំនួន៦៥នាក់ រងរបួសជាង៥០០នាក់ បានចាប់ខ្លួនដាក់ពន្ធនាគារ និងធ្វើទារុណកម្មជាង៨០០០នាក់ កាត់ទោសប្រហារជីវិតចំនួន៣នាក់ គឺ លោក ថាច់ គីន លោក ថាច់ ជៀក និងលោក គឹម វី ។ ជាប់គុកអស់មួយជីវិតចំនួន៦នាក់ គឺ ១-លោក សឺន ញ៉ ២-លោក កៀង សើង ៣-លោក កៀង ហាន ៤-លោក ថាច់ ជេន ៥-លោក ថាច់ សឺន ៦-លោក កៀង សួន ។ ជាប់គុក២០ឆ្នាំចំនួន៤នាក់ ១៥ឆ្នាំចំនួន៤នាក់ ១៣ឆ្នាំម្នាក់ ៥ឆ្នាំម្នាក់ និង៣ឆ្នាំម្នាក់ ។

២-បង្ហាញឲ្យសហគមន៍អន្តរជាតិឃើញថា ទឹកដីកម្ពុជាក្រោមជាទឹកដីដែលមានម្ចាស់ពិតប្រាកដ គឺ ខ្មែរ ។ ចាប់តាំងពីមានវត្តមានជនជាតិយួននៅលើទឹកដីខ្មែរដំបូងបង្អស់ឆ្នាំ១៦២៣ តាមរយៈព្រះរាជអគ្គមហេសីព្រះបាទ


ទីស្នាក់ការបណ្តោះអាសន្នផ្ទះលេខ: 10B ផ្លូវលេខ 234 សង្កាត់ទឹកល្អក់ ៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទលេខ: (៨៥៥) ១២ ៩០៨ ៨៨២ / ០៩០ ៩៧៧ ០០៧
E-mail: senthach2000@yahoo.com; Website: http//khmerkromngo.org

ដ៏យជេដ្ឋាទី២ ឈ្មោះ ង្វៀង ម៉ុកភ៉ុង បុត្រីទី៩ (កូដីន) របស់ស្តេចយួនឈ្មោះ ង្វៀង សាយឡឿង រហូតមកស្ទើរតែរាល់រជ្ជកាលព្រះមហាក្សត្រខ្មែរតែងតែធ្វើការតស៊ូបណ្តេញពួកអន្តោប្រវេសន៍យួនខុសច្បាប់ទាំងនោះ ឲ្យចេញពីទឹកដីខ្មែរជារៀងរហូត ។ នៅឆ្នាំ១៩៤៩ បារាំងបានប្រើប្រាស់អំណាចអាណានិគមនិយមរបស់ខ្លួន ពុះច្រៀកទឹកដីខ្មែរប៉ែកខាងក្រោម (កម្ពុជាក្រោម) ដែលមានផ្ទៃដីចំនួន៦៨៩៦៥គីឡូម៉ែត្រក្រឡា ផ្ទេរឲ្យអាណានិគមយួនត្រួតត្រាបន្តក៏ដោយ ក៏ព្រះមហាក្សត្រខ្មែរ និងប្រជារាស្ត្រខ្មែរពុំដែលទទួលស្គាល់ម្តងណាឡើយ ហើយចាត់ទុកថាទង្វើរបស់អាណានិគមបារាំង ជាទង្វើខុសច្បាប់ ។ យើងសូមបញ្ជាក់ជាគតិយុត្តិថា ទឹកដីកម្ពុជាក្រោម មិនមែនដូចទឹកដីរដ្ឋល្វីស៊ីយ៉ាណា នៅសហរដ្ឋអាមេរិក ដែលបារាំងបានលះបង់ឲ្យអាមេរិកនៅឆ្នាំ១៨០៣ រដ្ឋអាឡាស្កាសូវៀតបានលះបង់ឲ្យអាមេរិកនៅឆ្នាំ១៨៦៧ ឬដូចរដ្ឋក្បូលិន ដែលអេស្ប៉ាញបានលះបង់ឲ្យអាល្លឺម៉ង់ នៅឆ្នាំ១៨៩៩ នោះទេ ។ ព្រោះទឹកដីកម្ពុជាក្រោមមិនដែលមានសន្ធិសញ្ញា អនុសញ្ញា ឬកិច្ចព្រមព្រៀងណាមួយ ដែលធ្វើឡើងដោយព្រះរាជាណាចក្រកម្ពុជា ក្នុងការប្រគល់ទៅឲ្យប្រទេសវៀតណាមនោះទេ ហើយក៏មិនដែលបោះបង់ចោលដោយមិនបានការទាមទារ ឬតស៊ូយកមកវិញនោះដែរ ដូចព្រឹត្តិការណ៍ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៧៦នេះជាភស្តុតាងស្រាប់ ។

បពិត្រព្រះករុណាគ្រប់ព្រះអង្គជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត !

បងប្អូនរួមឈាមទាំងអស់ជាទីស្រឡាញ់ដ៏ជ្រាលជ្រៅ !

ក្នុងនាមអង្គការ-សមាគមខ្មែរកម្ពុជាក្រោម និងក្នុងនាមខ្ញុំព្រះករុណាខ្ញុំផ្ទាល់ សូមសម្តែងនូវកតញ្ញុតាធម៌ និងគោរពយ៉ាងជ្រាលជ្រៅចំពោះវិញ្ញាណក្ខន្ធវីរយុទ្ធជន យុទ្ធនារីខ្មែរស្នេហាជាតិដែលពលីជីវិត ក្នុងបុព្វហេតុសិទ្ធិសេរីភាព និងមាតុភូមិកម្ពុជាក្រោម ក្នុងព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រថ្ងៃទី១៦ វិច្ឆិកា ១៩៧៦ ។ ជាមួយគ្នានេះដែរ យើងខ្ញុំសូមគោរព និងកោតសរសើរដោយស្មោះអស់ពីដួងចិត្ត ចំពោះវីរភាពដ៏អង់អាចក្លាហាននៃវីរខេមរកុលបុត្រដែលបានចូលរួមដោយគ្មានរួញរា ក្នុងការទាមទារសិទ្ធិសេរីភាពជូនជនរួមឈាមខ្មែរកម្ពុជាក្រោម កាលពី៣៣ឆ្នាំមុន ។ បច្ចុប្បន្ន ខ្លះមានជីវិតរស់នៅ ខ្លះធ្លាក់ខ្លួនពិការ ខ្លះទៀតវិកលចរិតដែលគួឲ្យអាណិតអាសូរជាទីបំផុត ប៉ុន្តែទោះបីស្ថានភាពជីវិតរស់នៅធ្លាក់ក្នុងស្ថានភាពលំបាកវេទនាយ៉ាងណាក៏ដោយ ក៏វីរខេមរកុលបុត្រកម្ពុជាក្រោមរបស់យើងនៅតែបន្តការតស៊ូ ដើម្បីជាតិមាតុភូមិខ្មែរជារៀងរហូត មិនដែលបោះបង់ចោលម្តងណាឡើយ ។ យើងខ្ញុំចងចាំជានិច្ច ហើយអ្នកកត់ត្រាប្រវត្តិសាស្ត្រក៏មិនអាចកត់រំលងនូវព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រដែលកុលបុត្រកុលធីតាខ្មែរកម្ពុជាក្រោម បានបង្កើតឡើងនោះដែរ ។

ដើម្បីជាសក្ខីភាពក្នុងការគោរព និងដឹងគុណចំពោះវីរភាពស្នេហាជាតិដ៏ឧត្តុង្គឧត្តម និងការលះបង់សាច់ស្រស់ឈាមស្រស់របស់វីរយុទ្ធជន យុទ្ធនារីខ្មែរកម្ពុជាក្រោមដែលពលីជីវិតក្នុងព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រ ថ្ងៃ១៦ វិច្ឆិកា ១៩៧៦ និងវីរបុរស វីរសមណៈ វីរយុទ្ធជន យុទ្ធនារីខ្មែរស្នេហាជាតិដែលបានតស៊ូប្តូរជីវិតក្នុងបុព្វជាតិសាសនា និងមាតុភូមិកម្ពុជាក្រោម ថ្ងៃនេះយើងខ្ញុំបាននិមន្តព្រះសង្ឃរាប់បាត្រចំនួន១០៣អង្គ និងធារបង្សុកូលឧទ្ទិសកុសលប្រគេន និងជូនព្រះវិញ្ញាណក្ខន្ធ និងវិញ្ញាណក្ខន្ធ វីរសមណៈ វីរបុរស យុទ្ធជនយុទ្ធនារីខ្មែរស្នេហាទាំងអស់ ដោយសេចក្តីគោរពដ៏ខ្ពង់ខ្ពស់បំផុត ។ ដោយឥតមនុញ្ញផលនៃមនសិការស្នេហាជាតិដ៏ថ្លៃថ្នូ និងបុញ្ញកុសលដែលកើតមាននាពេលនេះ សូមព្រះវិញ្ញាណក្ខន្ធ និងវិញ្ញាណក្ខន្ធ វីរសមណៈ វីរបុរស យុទ្ធជនយុទ្ធនារីខ្មែរទាំងអស់ បានទៅសោយសុខក្នុងសុគតិភពកុំបីខាន ។ សូមគោរពប្រគេនពរ និងជូនពរព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងបងប្អូនរួមជាតិកម្ពុជាក្រោមទាំងអស់ទទួលបាននូវសិទ្ធិសេរីភាពពេញលេញ និងបានប្រកបទៅដោយ ពុទ្ធពរទាំង៤ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៩*